ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
**KINGDOM OF CAMBODIA**
**Nation - Religion - King**

ក្រសួងពាណិជ្ជកម្ម
**Ministry of Commerce**

លេខ៣៧៤៥០ព.ណ.ខ.ក.ល

ភ្នំពេញ, ថ្ងៃទី ១២ ខែ សីហា ឆ្នាំ ២០១៧

# សេចក្តីប្រកាសព័ត៌មាន
## ស្តីពីការធ្វើបច្ចុប្បន្នភាព
## ប្រព័ន្ធស្វ័យប្រវត្តិកម្ម ចេញវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញ

ក្រសួងពាណិជ្ជកម្ម មានកិត្តិយសសូមជម្រាបជូនដល់សាធារណៈជន និងក្រុមហ៊ុននាំចេញ-នាំចូល ឲ្យបានជ្រាបថា៖ ស្របតាមយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលកម្ពុជា ក្រសួងពាណិជ្ជកម្ម បានធ្វើការកែទម្រង់ស៊ីជម្រៅជាបន្តបន្ទាប់ សំដៅពង្រឹងយន្តការ និងប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ ជូនដល់វិស័យឯកជនឲ្យកាន់តែមានភាពងាយស្រួល និងរហ័ស ធានាដល់បរិយាកាសនៃការធ្វើធុរកិច្ចនៅកម្ពុជា កាន់តែល្អប្រសើរ។ ក្នុងចំណោមវិធានការណ៍ និងកំណែទម្រង់ជាច្រើន ដែលបានដាក់ចេញ និងទទួលបានប្រសិទ្ធភាពខ្ពស់ កាលពីថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៦ ក្រសួងពាណិជ្ជកម្ម បានចេញប្រកាសលេខ ៣១៩៨ ព.ណ.ខកល ស្តីពីការកំណត់នីតិវិធីនៃការស្នើសុំ និងចេញវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញគ្រប់ទម្រង់តាមប្រព័ន្ធស្វ័យប្រវត្តិកម្ម (Automation) ដើម្បីអនុញ្ញាតឲ្យក្រុមហ៊ុននាំចេញ-នាំចូល ធ្វើការទូទាត់កម្រៃសេវាសាធារណៈជូនរដ្ឋ តាមគណនីនៃធនាគារឯកជនទៀតផង។ ប្រព័ន្ធស្វ័យប្រវត្តិកម្មនេះ បានដំណើរការដោយរលូន ហើយបានកាត់បន្ថយពេលវេលា និងការចំណាយមិនចាំបាច់នានា យ៉ាងមានប្រសិទ្ធភាព។

នាពេលថ្មីៗនេះ អាស្រ័យដោយសារកំណើននៃការដាក់ពាក្យស្នើសុំវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញ និងការទូទាត់កម្រៃសេវាសាធារណៈ តាមប្រព័ន្ធស្វ័យប្រវត្តិកម្មមានកើនឡើងខ្ពស់ បានធ្វើឲ្យសមត្ថភាពនៃមជ្ឈមណ្ឌលរក្សាទុកទិន្នន័យនៃប្រព័ន្ធស្វ័យប្រវត្តិកម្ម មានភាពចង្អៀត និងរអាក់រអួល ដែលជាហេតុធ្វើឲ្យការផ្តល់វិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញ ដល់អ្នកនាំចេញមានការយឺតយ៉ាវ។

ក្រសួងពាណិជ្ជកម្ម សូមការអធ្យាស្រ័យពីសាធារណៈជន លើបញ្ហានេះ ហើយក្រសួងកំពុងតែកែលម្អប្រព័ន្ធទុកទិន្នន័យឲ្យបានប្រសើរឡើងវិញ ដើម្បីធានាឲ្យការស្នើសុំវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម នាំចេញទំនិញ មានភាពរលូន និងកាន់តែមានប្រសិទ្ធភាពខ្ពស់។

ក្រសួងពាណិជ្ជកម្ម សង្ឃឹមថា សាធារណៈជន និងក្រុមហ៊ុននាំចេញ-នាំចូល ទាំងអស់ ពិតជាមានការយោគយល់ និងបន្តសហការជាមួយក្រសួង ដើម្បីពង្រឹងការផ្តល់សេវាសាធារណៈ និងយន្តការនៃសហប្រតិបត្តិការលើភាពជាដៃគូរវាងរាជរដ្ឋាភិបាល និងវិស័យឯកជន ឲ្យកាន់តែមានប្រសិទ្ធភាពថែមទៀត៕

**សូមអរគុណ!**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ៣១៩៨ ព.ណ. ឧ.កណ

# ប្រកាស
## ស្តីពី
## នីតិវិធីនៃការស្នើសុំ និងការចេញវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញគ្រប់ទម្រង់តាមប្រព័ន្ធស្វ័យប្រវត្តកម្ម

## រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ១៣១ អនក្រ.បក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- បានឃើញបទបញ្ជាលេខ ០៤ បប ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្តីពីការពង្រឹងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធរបស់រាជរដ្ឋាភិបាល
- បានឃើញប្រកាសលេខ ១១២ MOC/SM 2013 ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនីតិវិធីចេញវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញ
- បានឃើញប្រកាសអន្តរក្រសួងលេខ ២៣៣ ព.ណ បអព.ប្រក ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនីតិវិធីក្នុងការបំពេញបែបបទនាំចេញទំនិញទៅក្រៅប្រទេស
- បានឃើញប្រកាសរួមលេខ ១៦៤៣ សហវ. ប្រក ចុះថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១៤ ស្តីពីការកែប្រែកម្រងសេវាសាធារណៈនៃតារាងឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសរួមលេខ ៩៨៥ សហវ.ប្រក ចុះថ្ងៃទី ២៨ ខែធ្នូ ឆ្នាំ២០១២ ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងពាណិជ្ជកម្ម។

- បានឃើញប្រកាសលេខ ១៦១ ព.ណ ពពក.ប្រក ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៤ ស្តីពីការដាក់ឲ្យអនុវត្តសាកល្បងនូវការដាក់ពាក្យស្នើសុំវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញតាមប្រព័ន្ធអេឡិចត្រូនិច
- យោងតម្រូវការចាំបាច់របស់ក្រសួងពាណិជ្ជកម្ម

## សម្រេច

**ប្រការ ១** :

ត្រូវបានដាក់ឲ្យអនុវត្តនូវការបំពេញបែបបទស្នើសុំ និងផ្តល់វិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញគ្រប់ទម្រង់តាមប្រព័ន្ធស្វ័យប្រវត្តកម្ម (Automation System) ក្នុងគោលបំណងសម្រួលដល់ការធ្វើពាណិជ្ជកម្ម និងបំពេញបានតាមលក្ខខណ្ឌតម្រូវនៃវិធានប្រភពដើមទំនិញរបស់ប្រទេសនាំចូល។

**ប្រការ ២** :

ផលិតករ ឬអ្នកនាំចេញ ដែលបានចុះឈ្មោះសុំប្រើប្រាស់ប្រព័ន្ធស្វ័យប្រវត្តកម្មសម្រាប់ស្នើសុំវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញទម្រង់ "អេ" អាចស្នើសុំវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញគ្រប់ទម្រង់ ឧបសម្ព័ន្ធជំនួសវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញ ឬឧបសម្ព័ន្ធដែលមិនតម្រូវឲ្យចេញវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញ។

រីឯផលិតករ ឬអ្នកនាំចេញ ដែលពុំធ្លាប់បានចុះឈ្មោះសុំប្រើប្រាស់ប្រព័ន្ធស្វ័យប្រវត្តកម្មសម្រាប់ស្នើសុំវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញទម្រង់ "អេ" ហើយមានបំណងស្នើសុំវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញទម្រង់ផ្សេងទៀត ឧបសម្ព័ន្ធជំនួសវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញ ឬឧបសម្ព័ន្ធដែលមិនតម្រូវឲ្យចេញវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញ ត្រូវចុះឈ្មោះសុំប្រើប្រាស់ប្រព័ន្ធស្វ័យប្រវត្តកម្ម តាមរយៈគេហទំព័រ "www.co.moc.gov.kh" របស់ក្រសួងពាណិជ្ជកម្ម ដោយបញ្ចូលព័ត៌មាន និងឯកសារតម្រូវទៅក្នុងប្រព័ន្ធស្វ័យប្រវត្តកម្ម ដូចខាងក្រោម៖

- ឈ្មោះក្រុមហ៊ុន និងអាសយដ្ឋាន
- វិញ្ញាបនបត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងសម្រង់ក្រុមហ៊ុន (ស្កេនច្បាប់ដើម)
- វិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជីក្នុងប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម (ស្កេនច្បាប់ដើម)
- បញ្ជីឈ្មោះមុខទំនិញនាំចេញ
- តារាងថ្លៃដើមផលិតផល (Cost Breakdown) ឬឯកសារយោងតាមការកំណត់របស់វិធានប្រភពដើមទំនិញ
- លិខិតប្រគល់សិទ្ធិពីប្រធានក្រុមហ៊ុន ឬនាយកគ្រប់គ្រង ក្នុងការចុះឈ្មោះ ចុះហត្ថលេខាលើពាក្យស្នើសុំ និងលើវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញ (ផ្តិតរូបភាព (Scan) ពីច្បាប់ដើម)
- អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែនរបស់អ្នកប្រគល់សិទ្ធិ និងទទួលសិទ្ធិ និងរូបថតទំហំ ៤x៦ ចំនួន ០១សន្លឹក (ផ្តិតរូបភាព (Scan) ពីច្បាប់ដើម)
- ឯកសារផ្សេងៗទៀត តាមការការកំណត់ដោយបញ្ញត្តិច្បាប់ (ផ្តិតរូបភាព (Scan) ពីច្បាប់ដើម)

**ប្រការ ៣** :

ផលិតករ ឬអ្នកនាំចេញ ដែលបានចុះឈ្មោះសុំប្រើប្រាស់ប្រព័ន្ធស្វ័យប្រវត្តកម្មរួចហើយ អាចដាក់ពាក្យស្នើសុំវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញគ្រប់ទម្រង់ ឬឧបសម្ព័ន្ធជំនួសវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញ តាមប្រព័ន្ធស្វ័យប្រវត្តកម្ម និងត្រូវភ្ជាប់មកជាមួយនូវឯកសារច្បាប់ដើមដូចខាងក្រោមៈ

- វិក្កយបត្រ (Invoice)
- តារាងវេចខ្ចប់ (Packing List)
- តារាងថ្លៃដើមផលិតផល (Cost Breakdown) ឬឯកសារយោងតាមការកំណត់របស់វិធានប្រភពដើមទំនិញ
- របាយការណ៍របស់មន្ត្រីជំនាញក្រសួងពាណិជ្ជកម្ម ស្តីពីការត្រួតពិនិត្យទំនិញនាំចេញ ដែលមានពណ៌ប៉ាវ៉ា ពណ៌បៃតង (ត្រេអ៊ី និងកាគី) ទំនិញដែលដឹកជញ្ជូនតាមរថយន្តឆ្លងកាត់ព្រំដែនកម្ពុជាទៅឡើងយន្តហោះនៅប្រទេសជិតខាង (Land-Air) ឬរបាយការណ៍ពិនិត្យទំនិញនាំចេញលើកដំបូង
- ឯកសារផ្សេងៗទៀត តាមតម្រូវការរបស់ប្រទេសនាំចូលដោយអនុលោមតាមវិធានប្រភពដើមទំនិញ។

ក្នុងករណីផលិតករ ឬអ្នកនាំចេញ ដែលបាននាំចេញទំនិញ ហើយមិនតម្រូវឲ្យសុំវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញ ចាំបាច់ត្រូវបំពេញឧបសម្ព័ន្ធក្នុងប្រព័ន្ធស្វ័យប្រវត្តកម្ម និងភ្ជាប់នូវឯកសារដូចខាងក្រោមៈ

- វិក្កយបត្រ (Invoice)
- តារាងវេចខ្ចប់ (Packing List)

បន្ទាប់ពីទទួលបានការឯកភាពរួចហើយ ផលិតករ ឬអ្នកនាំចេញ ត្រូវភ្ជាប់មកជាមួយនូវអញ្ញត្តិប័ណ្ណដឹកជញ្ជូន និងកំណត់ហេតុរួមស្តីពីការត្រួតពិនិត្យទំនិញ វាយនភ័ណ្ឌនាំចេញរបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា និងអគ្គនាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញនីហរ័ណអាហរ័ណ និងបង្ក្រាបការក្លែងបន្លំ (កាំកុងត្រូល) នៅពេលយកឧបសម្ព័ន្ធមកសុំតម្កល់ទុកនៅក្រសួងពាណិជ្ជកម្ម។

**ប្រការ ៤** :

នៅពេលដាក់ពាក្យស្នើសុំវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញ តាមប្រព័ន្ធស្វ័យប្រវត្តកម្ម ផលិតករ ឬអ្នកនាំចេញ ត្រូវទូទាត់កម្រៃសេវាសាធារណៈតាមប្រព័ន្ធអេឡិចត្រូនិចរបស់ធនាគារ ផ្អែកតាមការកំណត់ក្នុងប្រកាសរួម លេខ ១៦៤៣ សហវ.ប្រក ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៤ រវាងក្រសួងពាណិជ្ជកម្ម និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងលិខិតបទដ្ឋានពាក់ព័ន្ធផ្សេងទៀតជាធរមាន។ បង្កាន់ដៃបង់ប្រាក់ដែលបញ្ជាក់អំពីចំនួនទឹកប្រាក់បានបង់ចូលគណនីរបស់ក្រសួងពាណិជ្ជកម្ម ត្រូវបោះពុម្ពចេញឬរក្សាទុកឲ្យបានគត់មត់ដើម្បីជាភស្តុតាងបញ្ជាក់ថាពិតជាបានធ្វើការទូទាត់ប្រាក់រួចហើយ។

ការទូទាត់កម្រៃសេវាសាធារណៈតាមប្រព័ន្ធអេឡិចត្រូនិចរបស់ធនាគារ ត្រូវគិតជាប្រាក់រៀល។ ក្នុងករណីកម្រៃសេវាមួយចំនួនមានកំណត់ជាដុល្លារអាមេរិកនោះ ត្រូវប្តូរមកជាប្រាក់រៀលគិតតាមអត្រាប្តូរប្រាក់ប្រចាំថ្ងៃរបស់ធនាគារជាតិនៃកម្ពុជា។

**ប្រការ ៥** :

ក្រោយទទួលបានការឯកភាពពីក្រសួងពាណិជ្ជកម្ម តាមប្រព័ន្ធស្វ័យប្រវត្តកម្ម ផលិតករ ឬអ្នកនាំចេញ ត្រូវបោះពុម្ពវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញគ្រប់ទម្រង់ ឬឧបសម្ព័ន្ធជំនួសវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញ និងយកមកនាយកដ្ឋាន នាំចេញ-នាំចូលនៃក្រសួងពាណិជ្ជកម្ម ដើម្បីដាក់ជូនថ្នាក់ដឹកនាំក្រសួងពាណិជ្ជកម្មចុះហត្ថលេខា។

ក្នុងករណីដែលផលិតករ ឬអ្នកនាំចេញ មិនអាចបោះពុម្ពលើវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញគ្រប់ទម្រង់ ឬឧបសម្ព័ន្ធជំនួសវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញដោយខ្លួនឯងបាន អាចស្នើសុំឲ្យមន្ត្រីជំនាញនាយកដ្ឋាននាំចេញ-នាំចូល នៃក្រសួងពាណិជ្ជកម្ម ជួយបោះពុម្ពជំនួស។

ក្នុងករណី ផលិតករ ឬអ្នកនាំចេញ អាចបោះពុម្ពលើវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញដោយខ្លួនឯង ត្រូវមកបំពេញបែបបទស្នើសុំយកទម្រង់វិញ្ញាបនបត្រ (Blank Form) ពីនាយកដ្ឋាននាំចេញ-នាំចូលនៃក្រសួងពាណិជ្ជកម្ម និងត្រូវធ្វើរបាយការណ៍ពីការប្រើប្រាស់មកកាន់នាយកដ្ឋាននាំចេញ-នាំចូលនៃក្រសួងពាណិជ្ជកម្ម នៅសប្តាហ៍ទីមួយ នៃខែបន្ទាប់។

**ប្រការ ៦** :

ផលិតករ ឬអ្នកនាំចេញ ត្រូវផ្ញើឯកសារច្បាប់ដើមដូចមានកំណត់ខាងក្រោមជូននាយកដ្ឋាននាំចេញ-នាំចូលនៃក្រសួងពាណិជ្ជកម្ម ដើម្បីផ្ទៀងផ្ទាត់ និងតម្កល់ទុក ក្នុងរយៈពេល ៣០ថ្ងៃ បន្ទាប់ពីក្រសួងពាណិជ្ជកម្មបានចេញវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញ៖

សម្រាប់ទំនិញសម្លៀកបំពាក់ ផលិតផលវាយនភ័ណ្ឌ ស្បែកជើង និងផលិតផលផ្សេងទៀត៖

- វិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញគ្រប់ទម្រង់ ឬឧបសម្ព័ន្ធជំនួសវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញ (ច្បាប់ថតចម្លង)
- វិក្កយបត្រ (Invoice)
- តារាងវេចខ្ចប់ (Packing List)
- អញ្ញត្តិប័ណ្ណដឹកជញ្ជូន
- កំណត់ហេតុរួម ស្តីពីការត្រួតពិនិត្យទំនិញវាយនភ័ណ្ឌនាំចេញ របស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា និងអគ្គនាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញនីហរ័ណអាហរ័ណ និងបង្ក្រាបការក្លែងបន្លំ (កាំកុងត្រូល)។

សម្រាប់ផលិតផល សិប្បកម្ម កសិកម្ម នេសាទ និងផលិតផលផ្សេងទៀត៖

- វិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញគ្រប់ទម្រង់ ឬឧបសម្ព័ន្ធជំនួសវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញ (ច្បាប់ថតចម្លង)
- វិក្កយបត្រ (Invoice)
- តារាងវេចខ្ចប់ (Packing List)
- អញ្ញត្តិប័ណ្ណដឹកជញ្ជូន
- វិញ្ញាបនបត្របញ្ជាក់បរិមាណទំនិញនាំចេញ (CQ) ឬរបាយការណ៍ត្រួតពិនិត្យរបស់អគ្គនាយកដ្ឋានកាំកុងត្រូល ឬប្រតិវេទន៍គយរបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា (CD) ឬឯកសារផ្លូវការបញ្ជាក់បានថាទំនិញត្រូវបាននាំចេញពីកម្ពុជា។

- ឯកសារពាក់ព័ន្ធរបស់ក្រុមហ៊ុនដែលអាចបញ្ជាក់ពីប្រភពដើមទំនិញ ដូចជាកិច្ចសន្យាទិញ-លក់ ក្នុងស្រុកជាដើម
- អាជ្ញាប័ណ្ណនាំចេញ (ច្បាប់ថតចម្លង) ចំពោះទំនិញដែលច្បាប់តម្រូវឲ្យមានអាជ្ញាប័ណ្ណនាំចេញ

**ប្រការ ៧** :

ត្រូវបានកំណត់ថេរវេលាសរុបជាអតិបរមាក្នុងការផ្តល់វិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញគ្រប់ទម្រង់ រយៈពេល ១១ ម៉ោង ៥៥ នាទី នៃម៉ោងធ្វើការ ផ្អែកតាមតារាងឧបសម្ព័ន្ធទី ១ ភ្ជាប់នឹងប្រកាសរួមលេខ ១៦៤៣ សហវ.ប្រក ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៤ រវាងក្រសួងពាណិជ្ជកម្ម និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឬថេរវេលាថ្មី ដែលមានចែងក្នុងលិខិតបទដ្ឋានដែលនឹងត្រូវបានធ្វើវិសោធនកម្ម។

**ប្រការ ៨** :

ផលិតករ ឬអ្នកនាំចេញ ត្រូវបញ្ចូលទិន្នន័យនៃវត្ថុធាតុដើមនាំចូល និងវត្ថុធាតុដើមផលិតក្នុងស្រុក ទៅក្នុងប្រព័ន្ធស្វ័យប្រវត្តកម្មដោយភ្ជាប់មកជាមួយនូវឯកសារដូចខាងក្រោម៖

សម្រាប់វត្ថុធាតុដើមនាំចូល៖

- វិក្កយបត្រ មានប្រថាប់ត្រាគយ (ផ្តិតរូបភាព (Scan) ពីច្បាប់ដើម)
- តារាងវេចខ្ចប់ មានប្រថាប់ត្រាគយ (ផ្តិតរូបភាព (Scan) ពីច្បាប់ដើម)
- អញ្ញត្តិប័ណ្ណដឹកជញ្ជូន មានប្រថាប់ត្រាគយ (ផ្តិតរូបភាព (Scan) ពីច្បាប់ដើម)
- របាយការណ៍ត្រួតពិនិត្យរបស់អគ្គនាយកដ្ឋានកាំកុងត្រូល (ផ្តិតរូបភាព (Scan) ពីច្បាប់ដើម)
- លិខិតអនុញ្ញាតគយ និងប្រតិវេទន៍គយ របស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា (ផ្តិតរូបភាព (Scan)ពីច្បាប់ដើម)
- វិញ្ញាបនបត្របញ្ជាក់ប្រភពវត្ថុធាតុដើម (ផ្តិតរូបភាព (Scan) ពីច្បាប់ដើម)

សម្រាប់វត្ថុធាតុដើមផលិតក្នុងស្រុក៖

- លិខិតស្នើសុំអនុវត្តកិច្ចសន្យាទិញ-លក់វត្ថុធាតុដើម(ផ្តិតរូបភាព (Scan) ពីច្បាប់ដើម)
- កិច្ចសន្យាទិញ-លក់វត្ថុធាតុដើម (ផ្តិតរូបភាព (Scan) ពីច្បាប់ដើម)
- របាយការណ៍របស់មន្ត្រីជំនាញក្រសួងពាណិជ្ជកម្មអំពីការត្រួតពិនិត្យសង្វាក់ផលិតកម្មនៃរោងចក្រផ្គត់ផ្គង់ (ផ្តិតរូបភាព (Scan) ពីច្បាប់ដើម)
- វិក្កយបត្រ និងតារាងវេចខ្ចប់ (ផ្តិតរូបភាព (Scan) ពីច្បាប់ដើម)

ផលិតករ ឬអ្នកនាំចេញ ត្រូវផ្ញើឯកសារច្បាប់ដើមខាងលើ មកនាយកដ្ឋាននាំចេញ-នាំចូលនៃក្រសួង ពាណិជ្ជកម្ម ក្នុងរយៈពេល ៣០ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទនៃវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញ ឧបសម្ព័ន្ធជំនួសវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញ ឬឧបសម្ព័ន្ធដែលមិនតម្រូវឲ្យចេញវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញ ដើម្បីផ្ទៀងផ្ទាត់សមាមាត្ររវាងបរិមាណវត្ថុធាតុដើមនាំចូល ឬវត្ថុធាតុដើមផលិតក្នុងស្រុក ជាមួយបរិមាណទំនិញនាំចេញ សម្រាប់ការធ្វើអធិការកិច្ច។

ផលិតករ ឬអ្នកនាំចេញ ត្រូវធ្វើតារាងរបាយការណ៍ស្តីពីបទដ្ឋានប្រើប្រាស់វត្ថុធាតុដើម និងវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញ ឧបសម្ព័ន្ធជំនួសវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញ ឬឧបសម្ព័ន្ធដែលមិនតម្រូវឲ្យចេញវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញ (ច្បាប់ចម្លង)ដែលប្រើប្រាស់វត្ថុធាតុដើមទាំងនោះ ក្នុងរយៈពេល៣០ថ្ងៃ ក្រោយការនាំចេញមួយលើកៗ។

**ប្រការ ៩** :

ការធ្វើអធិការកិច្ចលើសង្វាក់ផលិតកម្ម និងផលិតផលនាំចេញ ដើម្បីធានាសង្គតភាពជាមួយវិធានប្រភពដើមទំនិញ ត្រូវធ្វើឡើងដោយមន្ត្រីជំនាញក្រសួងពាណិជ្ជកម្មនៅមូលដ្ឋានផលិតកម្ម និងឃ្លាំងស្តុកទំនិញ មិនឲ្យហួសពី៣០ (សាមសិប) ថ្ងៃ បន្ទាប់ពីទទួលបានវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញគ្រប់ទម្រង់ ឧបសម្ព័ន្ធជំនួសវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញ ឬឧបសម្ព័ន្ធដែលមិនតម្រូវឲ្យចេញវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញ ។

ការធ្វើអធិការកិច្ចលើមុខទំនិញកសិផល និងកសិផលកែច្នៃ ត្រូវអនុវត្តពីរដងក្នុងមួយឆ្នាំ លើកលែងតែទំនិញមានភាពមិនប្រក្រតី ឬចាំបាច់ត្រូវផ្ទៀងផ្ទាត់សង្គតភាពជាមួយវិធានប្រភពដើមទំនិញ។

ការធ្វើសារពើភ័ណ្ឌសន្និធិវត្ថុធាតុដើមក្នុងរោងចក្រ ត្រូវធ្វើឡើងដោយមន្ត្រីក្រសួងពាណិជ្ជកម្ម ចំនួន ០២ លើកក្នុងមួយឆ្នាំ (នៅក្នុងឆមាសទី១ និងឆមាសទី២) ឬអាចចុះផ្ទៀងផ្ទាត់ជាក់ស្តែងភ្លាមៗនៅពេលមានភាពមិនប្រក្រតី។

**ប្រការ ១០** :

ក្នុងករណី ដំណើរការនៃការអនុវត្តប្រព័ន្ធស្វ័យប្រវត្តកម្ម មានភាពអាក់អន្លលផ្នែកបច្ចេកទេស ឬកើតឡើងដោយប្រធានសក្តិ ផលិតករ ឬអ្នកនាំចេញ អាចស្នើសុំវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញគ្រប់ទម្រង់ ឧបសម្ព័ន្ធជំនួសវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញ ឬឧបសម្ព័ន្ធដែលមិនតម្រូវឲ្យចេញវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញក្រៅប្រព័ន្ធស្វ័យប្រវត្តកម្ម។

**ប្រការ ១១** :

មន្ត្រីទទួលបន្ទុក ត្រូវពិនិត្យផ្ទៀងផ្ទាត់ឯកសារយោង ដើម្បីធានាសុក្រឹតភាពតាមលក្ខខណ្ឌតម្រូវ និងផ្តល់ការយល់ព្រមលើឯកសារស្នើសុំវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញគ្រប់ទម្រង់ឧបសម្ព័ន្ធជំនួសវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញ ឬឧបសម្ព័ន្ធដែលមិនតម្រូវឲ្យចេញវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញ ជូនផលិតករ និងអ្នកនាំចេញតាមថេរវេលាកំណត់។

មន្ត្រីទទួលបន្ទុក ត្រូវពិនិត្យផ្ទៀងផ្ទាត់ឯកសារច្បាប់ដើមដែលផ្ញើមកសងដោយផលិតករ និងអ្នកនាំចេញ ក្រោយពីបានធ្វើការនាំចេញ។

**ប្រការ ១២** :

ផលិតករ ឬអ្នកនាំចេញ ត្រូវរួសរាន់ក្នុងការដាក់ពាក្យស្នើសុំឧបសម្ព័ន្ធដែលមិនតម្រូវឲ្យចេញវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញតាមប្រព័ន្ធស្វ័យប្រវត្តកម្ម និងបំពេញកាតព្វកិច្ចបង់ចំណូលនានាចូលថវិកាជាតិមិនឲ្យលើសពី៣០ថ្ងៃ

បន្ទាប់ពីទំនិញបានចេញរួច យោងតាមកាលបរិច្ឆេទមានបញ្ជាក់ក្នុងកំណត់ហេតុរួមរវាងអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា និងអគ្គនាយកដ្ឋានកាំកុងត្រូល។

ក្នុងករណីផលិតករ ឬអ្នកនាំចេញ មានការយឺតយ៉ាវ ខកខាន ឬគេងបន្លំការបំពេញកាតព្វកិច្ចបង់ចំណូលនានាចូលថវិកាជាតិ នឹងត្រូវទទួលការពិន័យ ២% (ពីរភាគរយ) ក្នុងមួយខែ លើតម្លៃគ្រប់គ្រងការនាំចេញ (EMF) ដែលត្រូវបង់ ឬអនុវត្តតាមលិខិតបទដ្ឋានដែលនឹងត្រូវបានធ្វើវិសោធនកម្ម ដូចមានកំណត់ក្នុងបទបញ្ជាលេខ ០៤ បប ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្តីពីការពង្រឹងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធរបស់រាជរដ្ឋាភិបាល ។

ក្នុងករណី ផលិតករ ឬអ្នកនាំចេញ យឺតយ៉ាវ ឬអាក់ខានមិនបានផ្ញើឯកសារជូនក្រសួងពាណិជ្ជកម្មតាមការកំណត់ដូចមានចែងក្នុងប្រការ ៦ និងប្រការ ៨ ខាងលើ ក្រសួងពាណិជ្ជកម្មនឹងផ្អាកជាបណ្តោះអាសន្ន ឬស្ថាពរនូវការចេញវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញ។

ក្នុងករណី ផលិតករ ឬអ្នកនាំចេញ ផ្ញើជូននូវឯកសារមិនត្រឹមត្រូវ ឬបន្លំឯកសារ ក្រសួងពាណិជ្ជកម្មនឹងចាត់វិធានការតាមច្បាប់ជាធរមាន។

**ប្រការ ១៣** :

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ១៤** :

នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធាននាយកដ្ឋាន តំណាងក្រសួងពាណិជ្ជកម្មប្រចាំរដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេស និងប្រធានអង្គភាពពាក់ព័ន្ធ ក្រោមឱវាទក្រសួងពាណិជ្ជកម្ម ត្រូវអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី២៦ ខែ សីហា ឆ្នាំ ២០១៦

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ប៉ាន សូរស័ក្តិ**

ចម្លងជូនៈ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី ស ខេង
- ខុទ្ទកាល័យ ឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- អាជ្ញាធរសេវាកម្មជាតិ
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- អង្គភាពប្រឆាំងអំពើពុករលួយ
- អគ្គនាយកដ្ឋានកាំកុងត្រូល
- អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា
- គ្រប់រដ្ឋបាលរាជធានី ខេត្ត
- សភាពាណិជ្ជកម្មកម្ពុជា
- សហព័ន្ធស្រូវអង្ករកម្ពុជា
- សមាគមរោងចក្រកាត់ដេរនៅកម្ពុជា

"**ដើម្បីជូនជ្រាប**"
- ដូចប្រការ ១៤ "**ដើម្បីអនុវត្ត**"
- ឯកសារ-កាលប្បវត្តិ